គណបក្ស សិទ្ធិមនុស្ស

HUMAN RIGHTS PARTY

បំរើ ការពារ កសាង


លេខ០៤៣៥/០៥...គ.ស.ម

ធ្វើនៅភ្នំពេញ. ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៥

# សេចក្តីថ្លែងការណ៍

តំណាងរាស្ត្រទាំងបីរូបគណបក្សសិទ្ធិមនុស្ស មិនចូលរួមប្រជុំសភាថ្ងៃនេះគឺដើម្បីសម្តែងការមិនគាំទ្រនូវគោលការណ៍ក្នុងការដក ឬព្យួរអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ ។

**គណបក្សសិទ្ធិមនុស្ស** ប្រឆាំងជំទាស់នឹងការដក ឬព្យួរអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ **សម រង្ស៊ី** ដែលបានសម្តែងមតិ ឬធ្វើសកម្មភាពការពារផលប្រយោជន៍ប្រជាពលរដ្ឋ ឬការពារផលប្រយោជន៍ជាតិ ។

**គណបក្សសិទ្ធិមនុស្ស** យល់ឃើញថា អភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រណាក៏ដោយទោះបីជាតំណាងរាស្ត្រមកពីគណបក្សកាន់អំណាច ឬគណបក្សជំទាស់ក្តី គឺជាសិទ្ធិពិសេសសំរាប់គេផ្តល់ឱ្យតំណាងរបស់ប្រជាពលរដ្ឋ ដើម្បីអាចធ្វើសកម្មភាពពេញលេញ ក្នុងការបំរើ និងការពារនូវឆន្ទះរបស់ប្រជាពលរដ្ឋ ដោយមិនអនុញ្ញាតឱ្យមានការចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនអ្នកតំណាងរាស្ត្រនោះដោយងាយៗ ព្រោះអ្នកតំណាងរាស្ត្រត្រូវធ្វើសកម្មភាពនិងសម្តែងមតិច្រើនលើសពីប្រជាពលរដ្ឋសាមញ្ញ ក្នុងការបំពេញតួនាទីរបស់ខ្លួន ។

**គណបក្សសិទ្ធិមនុស្ស** យល់ឃើញថា ការដក ឬព្យួរ ឬលើកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រយ៉ាងងាយៗ គឺជាការបន្ទាបតម្លៃអភ័យឯកសិទ្ធិ ក៏ដូចជាការបន្ទាបតម្លៃអ្នកតំណាងរាស្ត្រ និងឆន្ទះរបស់ប្រជាពលរដ្ឋខ្លួនឯង ដែលជាមូលហេតុអាចធ្វើឱ្យប៉ះពាល់ដល់គោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស និងការអភិវឌ្ឍន៍ជាតិ ។

*សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង*

*លេខទូរស័ព្ទ : ០១៦ ៤៣៥ ១០៦*


Address: #72-74, Street 598, Sangkat Boeung Kok 2, Khan Tuol Kok, Phnom Penh, Cambodia.

Tel: (+855) 17 303 900 / 023 884 649 | Email: hrpcambodia@yahoo.com| Website: www.hrpcambodia.info